ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ: ០០៦/១៩ [illegible] អ.ជ.ប.គ.ញ

ថ្ងៃពុធ ១២រោច ខែផល្គុន ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨ និងទិសដៅការងារ ឆ្នាំ២០១៩

(ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨)

អនុវត្តតាមផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៦-២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជាតាមស្មារតីនៃកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនកន្លងទៅ និងដើម្បីរួមចំណែកថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈទាំងនៅមុន និងក្រោយការបោះឆ្នោតជាតិ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ បានខិតខំអនុវត្តការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការបង្ការ ទប់ស្កាត់ និងដោះស្រាយរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀនរហូតទទួលបានលទ្ធផលគួរជាទីមោទនៈ ។

## I. សភាពការណ៍គ្រឿងញៀន

### ក. សភាពការណ៍គ្រឿងញៀនអន្តរជាតិ (1) ៖

ឆ្នាំ២០១៨ នេះ បញ្ហាគ្រឿងញៀនលើពិភពលោក នៅតែបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ទាំងសកម្មភាពផលិត ចរាចរ ជួញដូរ និងប្រើប្រាស់គ្រឿងញៀន គួរឲ្យព្រួយបារម្ភ។ ការផលិតគ្រឿងញៀនសំយោគមានការកើនឡើងឥតឈប់ឈរបើធៀបនឹងឆ្នាំកន្លងទៅ ។ អង្គការចាត់តាំងឧក្រិដ្ឋកម្មគ្រឿងញៀនថ្មីៗក៏បានកើតឡើងបន្ថែមទៀត និងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទពីតំបន់ផលិត ទៅកាន់ទីផ្សារគ្រឿងញៀនដែលមានតម្រូវការខ្ពស់ ។ ជាមួយនេះ សារធាតុញៀនថ្មី NPS( New Psychoactive Substances ) ដែលមានឥទ្ធិពលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទក៏មានការកើនឡើងជាច្រើនប្រភេទ ដែលពិភពលោកបាន និងកំពុងប្រឈមទៅនឹងការប្រើប្រាស់បំពាននូវសារធាតុនេះ ដោយហេតុថា សារធាតុទាំងនោះមួយចំនួនធំមិនទាន់ស្ថិតនៅក្រោមច្បាប់ត្រួតពិនិត្យ ឬអនុសញ្ញាអន្តរជាតិនៅឡើយ ។ និន្នាការនៃការប្រើបំពានគ្រឿងញៀនលើពិភពលោកមានការប្រែប្រួល ពីការប្រើប្រាស់គ្រឿងញៀនប្រភេទអាភៀន ហេរ៉ូ អ៊ីន កូកាអ៊ីន ទៅប្រើប្រាស់ប្រភេទគ្រឿងញៀនសំយោគ ។ ចំនួនអ្នកប្រើបំពានគ្រឿងញៀននៅលើពិភពលោកមានការកើនឡើងប្រមាណពី៥ ទៅ៦% នៃចំនួនប្រជាជនសរុបនៅទូទាំងពិភពលោក ដែលចំនួននេះមិនបានរាប់បញ្ចូលចំនួនអ្នកប្រើបំពានសារធាតុញៀនថ្មី ប្រភេទ NPS ( New Psychoactive Substances ) ផងនោះទេ ។

---
[1] សភាពការណ៍គ្រឿងញៀនអន្តរជាតិ និងក្នុងតំបន់ ដកស្រង់ពីរបាយការណ៍របស់ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ ( UNODC )



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨ ១ / ២៣

**ខ. សភាពការណ៍គ្រឿងញៀនក្នុងតំបន់ :**

តាមការវាយតម្លៃបញ្ហាគ្រឿងញៀននៅក្នុងតំបន់ មានស្ថានភាព និងការវិវត្តន៍ ដូចខាងក្រោម ៖

- ការផលិតគ្រឿងញៀននៅក្នុងតំបន់ត្រីកោណមាស នៅតែមានការកើនឡើងយ៉ាងខ្លាំង ពិសេសការផលិតគ្រឿងញៀនសំយោគ មេតំហ្វេតាមីនក្រាមម្សៅ និងមេតំហ្វេតាមីនគ្រាប់ ។ ចំណែកដំណាំអាភៀន មានការដាំដុះ និងផលិតតិចជាងគ្រឿងញៀនសំយោគ ដោយសារមានការលួចនាំចូលសារធាតុគីមីផ្សំទៅកាន់តំបន់ផលិតមានកំណើនខ្ពស់

- ការទំនាក់ទំនងពង្រីកទីផ្សារគ្រឿងញៀន រវាងក្រុមឧក្រិដ្ឋជននៅក្នុងតំបន់ត្រីកោណមាស ជាមួយក្រុមឧក្រិដ្ឋជននៅក្រៅតំបន់ ដូចជា ក្រុមអាហ្វ្រិកខាងលិច ក្រុមអូស្ត្រាលី ជាដើម ធ្វើឲ្យទីផ្សារគ្រឿងញៀនមានការរីករាលដាល ។ កត្តានេះ បានធ្វើឲ្យប្រទេសជាច្រើនរួមមានដូចជា ប្រទេសចិន អូស្ត្រាលី បង់ក្លាដេស រួមទាំងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ ឡាវ វៀតណាម និងកម្ពុជា បាននិងកំពុងទទួលរងផលប៉ះពាល់ពីការរីករាលដាលនេះ

- ការបង្ក្រាប និងចាប់យកគ្រឿងញៀន ក្នុងឆ្នាំ២០១៨ ដោយមន្ត្រីអនុវត្តច្បាប់៦ប្រទេសនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (ប្រទេសកម្ពុជា ចិន ឡាវ ភូមា ថៃ និងប្រទេសវៀតណាម) មានចំនួន មេតំហ្វេតាមីនគ្រាប់ (WY)= ៦៩.៩៥៤.៤៤៥គ្រាប់ មេតំហ្វេតាមីនក្រាមម្សៅ(Ice)= ១.២៧៩ គ.ក្រ កញ្ឆាក្រៀមៈ ៥.៣២៨ គ.ក្រ ហេរ៉ូអ៊ីន=១.៦៥១ គ.ក្រ និងសារធាតុគីមីផ្សំ=១០៤.៨៣៤ គ.ក្រ ។

**គ. សភាពការណ៍គ្រឿងញៀនកម្ពុជា :**

ដោយសារសភាពការណ៍គ្រឿងញៀនដូចខាងលើ ធ្វើឲ្យកម្ពុជានៅតែបន្តទទួលរងនូវផលប៉ះពាល់ពីការចរាចរឆ្លងកាត់គ្រឿងញៀន ដែលយើងអាចធ្វើការកត់សម្គាល់ដូចខាងក្រោម ៖

- ការចរាចរគ្រឿងញៀនចេញពីបណ្តាប្រទេសជិតខាង ភាគច្រើនគឺចូលតាមច្រកផ្លូវគោកនៃបណ្តាខេត្តនៅភាគឦសានប្រទេស ដែលបច្ចុប្បន្នសកម្មភាពគ្រឿងញៀនតាមច្រកនេះ មិនមានការថយចុះឡើយ
- ការចរាចរគ្រឿងញៀនចេញពីតំបន់អាមេរិកខាងត្បូង អឺរុប អាហ្វ្រិក និងអឌ្ឍចន្ទមាស ភាគច្រើនមានសកម្មភាពនៅតាមផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍
- តាមបញ្ញើប្រៃសណីយ៍ ក៏មានការលួចនាំចូលនូវស្លឹករុក្ខជាតិញៀនឈ្មោះខាត(KHAT)ចំនួន២ករណី ពីប្រទេសឥណ្ឌា និងអេត្យូពី ឆ្ពោះទៅសហរដ្ឋអាមេរិក ។ ជាមួយនឹងការចរាចរគ្រឿងញៀនឆ្លងកាត់ យើងបានកត់សម្គាល់ក្នុងរយៈពេលចុងក្រោយនេះ ការលបលួចដាំដុះដំណាំកញ្ឆាបានកើតមានតាមបណ្តាខេត្តមួយចំនួនផងដែរ។

# I. អំពីការងារដឹកនាំ

ក្នុងគោលបំណងចូលរួមរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ និងបន្ទប់ស្កាត់រាល់សកម្មភាពអសកម្មនានា ក៏ដូចជាការជំរុញអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពឲ្យកាន់តែសកម្មផុលផុស និងទទួលបាននូវប្រសិទ្ធភាពខ្ពស់ ចាប់តាំងពីថ្នាក់ដឹកនាំកំពូលថ្នាក់ជាតិ ក៏ដូចជាអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងថ្នាក់ក្រោមជាតិ បានរៀបចំកម្លាំង និងចាត់តាំងអនុវត្តដូចខាងក្រោម ៖

## ១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមរាជរដ្ឋាភិបាល ទាំងមុន និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៃរដ្ឋសភា នៅតែបន្តយកចិត្តទុកដាក់លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយបាន ៖

- ក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្រ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (ព្រះរាជក្រឹត្យនេះបានកែសម្រួលពីព្រះរាជក្រឹត្យចាស់លេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី២៥.៥.២០១៨)

- ផ្ញើសារលិខិតអប់រំពីបញ្ហាគ្រឿញៀន ជូនបងប្អូនជនរួមជាតិនៅក្នុងឱកាសនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

- ជួបសំណេះសំណាល និងបញ្ជ្រាបបញ្ហាគ្រឿងញៀន ដើម្បីជាការដាស់តឿនក្រើនរំលឹកដល់កម្មករកម្មការិនី នៅតាមរោងចក្រ សហគ្រាសនានាទូទាំងប្រទេស

- ប្រគល់ភារកិច្ចជូន **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. ក្នុងនាមរាជរដ្ឋាភិបាលឲ្យបន្តការដឹកនាំអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ដោយប្រមូលផ្តុំសមាសភាពពីគ្រប់មជ្ឈដ្ឋានសង្គម អនុវត្តនូវវិធានការសរុប ប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ក្នុងការពង្រឹងយន្តការដែលមានស្រាប់ និងរៀបចំយន្តការចាំបាច់បន្ថែម ក៏ដូចជាកសាងផែនការសកម្មភាពមួយចំនួនទៀត ដើម្បីអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវ និងកាន់តែទទួលបាននូវការចូលរួមគាំទ្រពីសាធារណមតិជាតិ និងអន្តរជាតិ ។

ជាមួយគ្នានេះ នៅក្នុងឱកាសអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ កន្លងទៅ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រ**កម្ពុជា និង ឯកឧត្តម នាយករដ្ឋមន្ត្រី** នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលវៀតណាម ក្នុងចំនួនទឹកប្រាក់៣លានដុល្លារអាមេរិក ។

## ២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ប្រធាន អ.ជ.ប.គ.ញ. បានណែនាំនូវគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តវិធានការយុទ្ធសាស្ត្រទាំង៧ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរួមមាន ១)-ការងារអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ២)-ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៣)-ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៤)-ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៥)-កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៦)-កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៧)-ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ក៏ដូចជាផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលឆ្នាំ២០១៧ ។

ក្រៅពីបានណែនាំទៅតាមវិធានការយុទ្ធសាស្ត្រនៃផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ និង ឯកឧត្តម អនុប្រធាន អ.ជ.ប.គ.ញ. ក៏បាន ៖

- ទទួលជួបជាមួយក្រុមប្រតិភូបច្ចេកទេសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រថៃ ពាក់ព័ន្ធនឹងការផ្តល់ជំនួយសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ

- បានដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការដុតបំផ្លាញវត្ថុតាងគ្រឿងញៀន (វត្ថុតាងគ្រឿងញៀនដុតបំផ្លាញមាននៅដើមទំព័រទី១០នៃរបាយការណ៍)
- បានជួបសំណេះសំណាលជាមួយមន្ត្រីរាជការ សិស្សានុសិស្ស និងប្រជាពលរដ្ឋ នៅខេត្តបន្ទាយមានជ័យ ពោធិ៍សាត់ និងបានធ្វើការបញ្ជ្រាបខ្លឹមសារអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន **២.៧៥០នាក់**
- ឯកឧត្តម នាយឧត្តមសេនីយ៍ ជួន សុវណ្ណ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញជាអធិបតីក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សាឆ្នាំ២០១៨-២០១៩ នៅវិទ្យាល័យឥន្ទ្រទេវី រាជធានីភ្នំពេញ
- ឯកឧត្តម នាយឧត្តមសេនីយ៍ ជួន សុវណ្ណ អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមកិច្ចប្រជុំទ្វេភាគី/ត្រីភាគី កម្ពុជា វៀតណាម ឡាវ ថ្នាក់រដ្ឋមន្ត្រី ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្នាំ២០១៨ នេះ យោងតាមផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ក៏ដូចជាការអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៧ យើងបានខិតខំអនុវត្តដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ជាមួយនឹងការណែនាំឱ្យជម្រុញការអប់រំផ្សព្វផ្សាយ ឱ្យបានកាន់តែសកម្មដល់គ្រប់សមាសភាពនៅក្នុងសង្គម តាមរយៈបណ្តាញព័ត៌មាន រួមមាន (ប្រព័ន្ធទូរស័ព្ទ ស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋ ឯកជន ការបិទផ្សាយខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍) ការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ និងការជួបជាមួយវិស័យឯកជន ។ល។ ក៏ដូចជាការយកចិត្តទុកដាក់លើក្រុមគោលដៅប្រឈម ដែលយើងបានវាយតម្លៃកាលពីឆ្នាំ២០១៧ថា ជាក្រុមគោលដៅដែលពិបាកផ្តល់ការអប់រំ មានដូចជា ក្រុមពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មករ-កម្មការិនីរោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា ។ល។ ព្រមទាំងបានធ្វើការបណ្តុះបណ្តាលជនបង្គោល ដើម្បីឱ្យពួកគាត់ជួយដល់ការងារអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន។ សម្រាប់ឆ្នាំ២០១៨នេះ យើងទទួលបានលទ្ធផលការងារដូចខាងក្រោម ៖

#### ១.១ ការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖

គ្រប់ក្រសួង-ស្ថាប័ន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដែលពាក់ព័ន្ធនឹងការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ បានចូលរួមផ្តល់កិច្ចសម្ភាសន៍ជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយដូចជា វិទ្យុ-ទូរទស្សន៍រដ្ឋ និងឯកជន ផលិតផលភាពយន្ត បណ្តាញទូរស័ព្ទចល័ត គេហទំព័រ បណ្តាញសារព័ត៌មានអេឡិកត្រូនិចជាដើម។ល។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ណែនាំឲ្យក្រុមហ៊ុនផលិតកម្មភាពយន្ត និងចម្រៀង ដំឡើងសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងផលិតផលរបស់ខ្លួន ដែលបានផ្តល់ទិដ្ឋាការឲ្យធ្វើអាជីវកម្ម បានចំនួន ៨.០៣០.៩៣៣ វីស៊ីឌី និង ឌីវីឌី ។

តាមរយៈគេហទំព័រ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានអ្នកចូលអានសរុប **៥៤២.១២៦** ដង ។

#### ១.២ កម្មវិធីអប់រំផ្សព្វផ្សាយតាមសហគមន៍ ៖

ការងារអប់រំផ្សព្វផ្សាយតាមសហគមន៍ យើងបានរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កម្មវិធីព្រះពុទ្ធសាសនាផ្សាភ្ជាប់នឹងសង្គម កិច្ចប្រជុំ សិក្ខាសាលា វេទិកាសាធារណៈ វេទិកាតុមូល ។ល។ នៅតាមវត្តអារាម គ្រឹះស្ថានអប់រំ រោងចក្រ-សហគ្រាស និងបានចែកចាយខិត្តប័ណ្ណពាក់ព័ន្ធនឹងការងារបង្ការ ទប់ស្កាត់ការចរាចរ ជួញដូរ រក្សាទុក ប្រើប្រាស់គ្រឿងញៀន និងការព្យាបាលអ្នកញៀនគ្រឿងញៀនជាប់ជាប្រចាំ ក្នុងនោះ ៖

**១.២.១.** បុគ្គលិក កម្មករ កម្មការិនីចំនួន **៨០០.០០០** នាក់ បានទទួលសារអប់រំគ្រឿងញៀនពី**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងពិធីជួបសំណេះសំណាលនៅតាមបណ្តារោងចក្រ។

**១.២.២.** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ. បានដឹកនាំប្រារព្ធ និងណែនាំឲ្យរាជធានី-ខេត្ត ចាត់តាំងប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានមហាជនចូលរួម **២៥.២៦៥** នាក់ ។

**១.២.៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. សហការជាមួយគោលដៅពាក់ព័ន្ធ បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន តាមរយៈវេទិកានានា មានមហាជនចូលរួម **៣៥៩.៦៩២** នាក់

**១.២.៤.** ក្រសួងសមាជិក អ.ជ.ប.គ.ញ. រួមមាន ៖ ក្រសួងអប់រំ យុវជន និងកីឡា , ក្រសួងកិច្ចការនារី , ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ , ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច , ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ , ក្រសួងធម្មការ និងសាសនា , ក្រសួងការពារជាតិ , ធនាគារជាតិនៃកម្ពុជា , ក្រសួងយុត្តិធម៌ , ក្រសួងទេសចរណ៍ , ក្រសួងសុខាភិបាល , ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំ **១.៩៧០.៧៨៩** នាក់ ក្នុងនោះ មានជនបង្គោល **១០.៥២៨** នាក់។

**១.២.៥.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចាត់តាំងអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀននៅក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក និងពិធីបុណ្យសម្ពោធវិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំប្រមាណ **១.៥០០.០០០** នាក់ ។

**១.២.៦.** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនទាំង២៥ រាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារអប់រំ **៥.២៨៨.២៣៩** នាក់ ។

➢ សរុបអ្នកដែលបានមកទទួលសារអប់រំពីបញ្ហាគ្រឿងញៀនចំនួន **៩.៩៤៣.៩៨៥** អង្គ/នាក់ មានការកើនឡើង ៣០៣.៩៦៤ នាក់ បើធៀបឆ្នាំ២០១៧(**៩.៦៤០.០២១នាក់**) ។

ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបែងចែកឯកសារផ្សព្វផ្សាយគ្រប់ប្រភេទដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងអង្គភាព រួមមាន ៖

- សៀវភៅច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៦.៣៥០ ក្បាល
- សៀវភៅចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ៤.០០០ ក្បាល
- សៀវភៅកម្រងសំណួរ ចម្លើយពីបញ្ហាគ្រឿងញៀន ៧.៥០០ ក្បាល
- ផ្ទាំងរូបភាពខ្នាតតូច ១៣.០០០ សន្លឹក
- ផ្ទាំងរូបភាពខ្នាតធំ ១២.៥០០ សន្លឹក
- Sticker ដែល អ.ជ.ប.គ.ញ. សហការផលិតរួមគ្នាជាមួយក្រសួងទេសចរណ៍ ១២.០០០ សន្លឹក
- ខិត្តប័ណ្ណផ្សព្វផ្សាយ ៣៥.៥០០ សន្លឹក
- ជញ្ជីង ៤៥ គ្រឿង

( សរុបរួមមានចំនួន **៩០.៨៥០** ក្បាល/សន្លឹក និងជញ្ជីង **៤៥** គ្រឿង )

ទន្ទឹមនេះ ក្រសួងទេសចរណ៍ បានដំឡើងប៉ាណូអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនចំនួន២០ផ្ទាំងថែមទៀតពីលើផ្ទាំងប៉ាណូដែលមានក្នុងឆ្នាំចាស់ ។ ឯក្រសួងសុខាភិបាលបានផលិតខិតប័ណ្ណពីផលប៉ះពាល់សុខភាពបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន និងបានផលិតផ្ទាំងរូបភាព ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍បាន ៣២.៥០០សន្លឹក ៣០០អាវយឺត និង៣៤ បដា។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ព្យាបាល ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

ជាមួយនឹងការណែនាំ ឱ្យបន្តពង្រឹងសេវាព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ(មណ្ឌលសុខភាព-មន្ទីរពេទ្យបង្អែក) ការពង្រឹងសមត្ថភាពមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ-ឯកជន និងការបន្តដំណើរការសាងសង់មជ្ឈមណ្ឌលជាតិផ្ដល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀននៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ យើងបានខិតខំអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួងសុខាភិបាលជាសេនាធិការ បាន ៖

– បន្តផ្ដល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យបង្អែកមានជ័យ រាជធានីភ្នំពេញ ក្នុងឆ្នាំ២០១៨នេះ មានអ្នកទៅទទួលសេវាព្យាបាលចំនួន ១២៦នាក់/ស្រី១៧នាក់

– ផ្ដល់ការគាំទ្រ និងអនុញ្ញាតឲ្យអង្គការក្រៅរដ្ឋាភិបាលចំនួន ២ អនុវត្តបន្តនូវកម្មវិធីម្ជុល/ស៊ីរ៉ាំង ដែលអាចគ្របដណ្ដប់ទៅលើអ្នកចាក់គ្រឿងញៀនចំនួន ៦៦២ នាក់។

ជាមួយគ្នានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្របសម្រួល និងចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. មន្ត្រីក្រសួង-ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធឲ្យទៅចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា វេទិកាអន្តរជាតិ ទាំងនៅក្នុង និងក្រៅប្រទេសសរុប ១៩ លើក ។

**កម្មវិធីសំខាន់ៗ មានជាអាទិ៍ ៖**

– កិច្ចប្រជុំគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ

– ទិន្នន័យអង្កេតស្រាវជ្រាវចំណេះដឹងស្ដីពីជំងឺអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀនឆ្នាំ២០១៧

– កិច្ចប្រជុំក្រុមប្រឹក្សាយោបល់មជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាប្រឆាំងមេរោគអេដស៍នៅអាស៊ីអាគ្នេយ៍

– សិក្ខាសាលាផ្សព្វផ្សាយស្ដីពីការយល់ដឹងជាទូទៅនៃឥទ្ធិពលគ្រឿងញៀនលើការរីករាលដាលនៃការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍

– ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៨ ។

### ២.២. ការងារព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៖

ឆ្នាំ២០១៨ នេះ ៖

– តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល យើងរកឃើញចំនួនអ្នកប្រើប្រាស់គ្រឿងញៀន មានប្រមាណជិត **២ម៉ឺន** នាក់ ក្នុងនោះ ៖

- **អ្នកប្រើគ្រឿងញៀន** ដែលបានធ្វើសមាហរណកម្មចេញពីមណ្ឌលរដ្ឋ និងឯកជន មាន **៨.៣៩៩** នាក់
- **អ្នកប្រើគ្រឿងញៀន** ដែលបានទទួលសេវាព្យាបាលតាមប្រព័ន្ធសុខាភិបាល មាន **៥.៣៩៦** នាក់
- **អ្នកប្រើគ្រឿងញៀន** ដែលបន្តធ្វើការបន្សាបព្យាបាលនៅតាមមណ្ឌលរដ្ឋ និងឯកជន មាន៤.៧៤៦ **នាក់**

– តាមរបាយការណ៍របស់លេខាធិការដ្ឋាន នៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ យើងរកឃើញចំនួនអ្នកប្រើប្រាស់គ្រឿងញៀន ដែលសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន មាន **៧.២០៩** នាក់ ។

➢ **កត់សម្គាល់** ៖ អ្នកប្រើប្រាស់គ្រឿងញៀន ដែលបានចូលមកទទួលយកសេវាបន្សាបព្យាបាលនៅតាមមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ និងឯកជន និងនៅតាមប្រព័ន្ធសុខាភិបាលមូលដ្ឋាន(ព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍) មានប្រមាណជិត**២ម៉ឺន**នាក់ បើធៀបទៅនឹងអ្នកប្រើប្រាស់គ្រឿងញៀនដែលសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនក្នុងឆ្នាំ២០១៨ មានប្រមាណ ជាង **៧៣ន់**នាក់ គឺអាចនិយាយបានថា នៅក្នុងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ នេះ មានអ្នកប្រើ និងអ្នកញៀនគ្រឿងញៀនប្រមាណជាង **១ម៉ឺន**នាក់ ដែលលាក់ខ្លួនពីសមត្ថកិច្ចកន្លង មកបានស្ម័គ្រចិត្តចេញទៅទទួលយកសេវាបន្សាបព្យាបាលនៅតាមមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ និងឯកជន និងនៅតាមប្រព័ន្ធសុខាភិបាលមូលដ្ឋាន ។

**ជាមួយនោះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន៖**

– បានជំរុញឲ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹង និងបង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញ និងគាំទ្រឲ្យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀនមានភាពងាយស្រួលទៅទទួលយកសេវាព្យាបាលនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែរទាំបន្តនៅតាមសហគមន៍

– ពង្រីកសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាលបាន **៤៣១** កន្លែង នៅទូទាំងប្រទេស ក្នុងនោះ ៖ មន្ទីរពេទ្យថ្នាក់ជាតិ២កន្លែង , មន្ទីរពេទ្យខេត្ត២៤កន្លែង , មន្ទីរពេទ្យបង្អែក៧៣កន្លែង និងមណ្ឌលសុខភាព៣៣២កន្លែង

➢ **កត់សម្គាល់ ៖ ណ្ឌលសុខភាពចំនួន១១ទើបដាក់ដំណើរការសេវាព្យាបាលអ្នកញៀនគ្រឿងញៀន នៅខេត្តព្រះវិហារ១០ទីតាំង និងនៅខេត្តស្ទឹងត្រែង០១ទីតាំង និងសេវាផ្ដល់ឱសថមេតាដូនជំនួស០១កន្លែងទៀតនៅមន្ទីរពេទ្យបង្អែកមានជ័យ រាជធានីភ្នំពេញ។**

– ដំឡើងស្លាកសញ្ញាសម្គាល់ទីតាំងផ្ដល់សេវាពិនិត្យព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន បាន ៣៤៥ ទីតាំង ស្មើនឹង ៨២% លើចំនួនទីតាំងផ្ដល់សេវាសរុប

– បន្តការសាងសង់មជ្ឈមណ្ឌលជាតិផ្ដល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

## ២.៣. ចក្ខុបំប៉នសមត្ថភាពលើការងារព្យាបាល និងស្ដារនីតិសម្បទា ៖

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធជាសមាជិក បានរៀបចំ ៖

– សិក្ខាសាលាស្ដីពីសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនចំនួន ៩ វគ្គ ដោយបានប្រមូលផ្ដុំគ្រូពេទ្យ និងគិលានុប្បដ្ឋាក មកពីមន្ទីរពេទ្យជាតិ ចំនួន២ និង២៥រាជធានី-ខេត្ត

– សិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីគោលការណ៍ប្រតិបត្តិសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ បានចំនួន ២ វគ្គ ។

– សិក្ខាសាលាប្រចាំតំបន់ ស្ដីពីការបង្ការមេរោគអេដស៍ក្នុងចំណោមអ្នកចាក់គ្រឿងញៀន

– កិច្ចប្រជុំតម្រង់ទិស ស្ដីពីការអនុវត្តគម្រោងសាកល្បងការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍

– កិច្ចប្រជុំភាពជាដៃគូរវាងវិស័យសុខាភិបាល រដ្ឋអំណាចមូលដ្ឋាន និងមន្ត្រីអនុវត្តច្បាប់ក្នុងការអនុវត្តការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ជាមួយនឹងការណែនាំឱ្យបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក៏ដូចជាការបង្កើនកិច្ចសហប្រតិបត្តិការទប់ ស្កាត់បញ្ហាគ្រឿងញៀន ការពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (BLO) ក៏ដូចការលើកកម្ពស់ជំនាញមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន យើងក៏បានខិតខំអនុវត្តការងារដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

### ៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

អ.ជ.ប.គ.ញ. បានសម្របសម្រួល រៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សាដកបទពិសោធន៍ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេសសរុប **៣៣** លើក ក្នុងនោះ បណ្តុះបណ្តាលនៅក្នុងប្រទេស ២៨ លើក និងនៅក្រៅប្រទេស ៥ លើក ។

**កម្មវិធីសំខាន់ៗ មានជាអាទិ៍ ៖**

– វគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តច្បាប់គ្រឿងញៀនដល់មន្ត្រីនគរបាលយុត្តិធម៌

– វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមប្រព័ន្ធអេឡិចត្រូនិច (e-Learning)

– វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT)

– ទស្សនកិច្ចសិក្សា ស្តីពីការរឹបអូសទ្រព្យ និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀននៅប្រទេសថៃ

– កម្មវិធីត្រួតពិនិត្យកុងតឺន័ររបស់អង្គការUNODCនៅកំពង់ផែសមុទ្រ និងបន្តវគ្គបណ្តុះបណ្តាលទ្រឹស្តីនៃការត្រួតពិនិត្យទំនិញតាមផ្លូវអាកាស នៅតាមអាកាសយានដ្ឋានអន្តរជាតិ

– សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន(BLO) និងការពង្រឹងសមត្ថភាពជាប្រព័ន្ធនៃការិយាល័យទំនាក់ទំនងព្រំដែន(BLO)

– បញ្ជូនមន្ត្រីទៅប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលគម្រោងសុវត្ថិភាពទន្លេមេគង្គ នៅប្រទេសចិន និងប្រទេសឡាវ

– កិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

– កិច្ចប្រជុំ ស្តីពីការត្រួតពិនិត្យទំនិញចរាចរតាមផ្លូវអាកាស

– ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការអង្គភាពត្រួតពិនិត្យទំនិញចរាចរតាមផ្លូវអាកាស

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន [1] ៖

– **បទល្មើសគ្រឿងញៀនសរុប** បង្ក្រាបបាន **៨.០០២** ករណី(ធៀបនឹងឆ្នាំ២០១៧ **៨.១៧៣** ករណី) ថយចុះ **១៧១** ករណី ស្មើនឹង ២,១០ % ក្នុងនោះ ៖

- ករណីជួញដូរ រក្សាទុក **៤.៩៧២** ករណី
- ករណីប្រើប្រាស់ **២.៩៨២** ករណី
- កែច្នៃ **២** ករណី
- ដាំដុះ **៤៦** ករណី

ក្នុងចំណោមករណីខាងលើ មានករណីធំៗដែលបង្ក្រាបបានសារធាតុញៀនចាប់ពី**១គក្រ.**ឡើង មានចំនួន**៤៧ករណី** ចាប់យកសារធាតុញៀនសរុប**៤៧២,៥៣គ.ក្រ** និងចាប់បានមេក្លោង**១៩នាក់** ខ្សែរយៈបណ្តាញ

1 ) បទល្មើស ជនសង្ស័យ វត្ថុតាងគ្រឿងញៀន ទ្រព្យសម្បត្តិ យកតាមតារាងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន

ចំនួន**៦៤នាក់** និងមាន២២ករណី បានបង្ក្រាបដោយសមត្ថកិច្ចចម្រុះនៅអាកាសយានដ្ឋានអន្តរជាតិ ដោយចាប់យកបានគ្រឿងញៀនជាច្រើន ។ ជាមួយនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក៏បានរកឃើញគ្រឿងញៀនជាច្រើនករណីតាមបញ្ញើប្រៃសណីយ៍ផងដែរ ។

– **ជនសង្ស័យសរុប** ឃាត់ខ្លួនមាន **១៦.២១៦** នាក់ / ស្រី **១.៣៣៣** នាក់(ធៀបជាមួយឆ្នាំ២០១៧ **១៧.៨០០** នាក់) ថយចុះ **១.៥៨៤** នាក់ ស្មើនឹង ៨,៩១ % ក្នុងនោះ ៖

- ជនសង្ស័យក្នុងករណីជួញដូរ រក្សាទុក **៨.៩៩៦** នាក់ (ស្រី ៩០៤ នាក់)
- ជនសង្ស័យក្នុងករណីប្រើប្រាស់គ្រឿងញៀន **៧.២០៩** នាក់ (ស្រី៤២៥នាក់)
- ជនសង្ស័យក្នុងករណីកែច្នៃ **៤** នាក់ (ភេទប្រុស)
- ជនសង្ស័យក្នុងករណីដាំដុះ **៧** នាក់ (ស្រី ៤ នាក់)

ជនសង្ស័យរួមមាន ៖ ជនជាតិ**ខ្មែរ ១៥.៨៨៥ នាក់(ស្រី១.២៩៥នាក់) និងជនបរទេស ៣៣១នាក់ (ស្រី៥០នាក់)** ស្មើនឹង២៥ជនជាតិ គឺ ៖ វៀតណាម ១៩០ នាក់(ស្រី៣៤នាក់) , ចិន ៥៦ នាក់(ស្រី៦នាក់), កូរ៉េ ១០នាក់, តៃវ៉ាន់ ៥នាក់, ឡាវ ១៥នាក់, ថៃ ២២នាក់(ស្រី៦នាក់),នីហ្សេរីយ៉ា ៣នាក់, ឥណ្ឌូនេស៊ី ៣នាក់, បារាំង ២នាក់, អង់គ្លេស ២នាក់(ស្រី១នាក់) , រុស្សី ២នាក់ , អៀកឡង់១នាក់ , ហ្វីលីពីន ២នាក់(ស្រី១នាក់) , អាហ្វ្រិកខាងត្បូង ១នាក់, អូស្ត្រាលី ១នាក់, អាមេរិក ១នាក់, ចិនហុងកុង ២នាក់, បែលហ្សិក ២នាក់, តួកគី ១នាក់, ម៉ាឡេស៊ី ៤នាក់, ឥណ្ឌា ១នាក់, ស្វីស ២នាក់, សឹង្ហបុរី ១នាក់ , អ៊ូបេគីស្ថាន ១នាក់(ស្រី) និងអ៊ីតាលី ១នាក់ ។

**គ្រឿងញៀនសំយោគច្រើនប្រភេទ រួមទាំងកញ្ឆាក្រៀម និងស្លឹករុក្ខជាតិខាត**(KHAT) **ដែលបានចាប់យក**សរុប ៣ តោន ៨៤៧ គ.ក្រ ៧១៤,៤៤ ក្រាម **ក្នុងនោះ ៖**

– **គ្រឿងញៀនសំយោគមាន ៨៣៦ គ.ក្រ ៣៨៤,៤៤ ក្រាម គឺ ៖**

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៣០៦ គ.ក្រ ៦៣០,៨៣ ក្រាម
- មេតំហ្វេតាមីនគ្រាប់ (WY) ៦ គ.ក្រ ៩២៦,៣០ ក្រាម
- អិចស្តាស៊ី ១៧៩ គ.ក្រ ៧៦០,៤២ ក្រាម
- ហេរ៉ូអ៊ីន ១ គ.ក្រ ៣២៨,៦២ ក្រាម
- កូកាអ៊ីន ៥ គ.ក្រ ៣៧៩,៧៥ ក្រាម
- កេតាមីន ៣៦ គ.ក្រ ៣២៨,៥២ ក្រាម

– **កញ្ឆាក្រៀម និងស្លឹករុក្ខជាតិខាត ៖**

- កញ្ឆាក្រៀម ៧៤ គ.ក្រ ០៤២ ក្រាម
- ដើមកញ្ឆា ១៦៤.៩២៥ ដើម
- ស្លឹករុក្ខជាតិខាត ៣.២៣៧ គ.ក្រ ៣៦០ ក្រាម

– **សម្ភារចាប់យក និងឃាត់ទុកនូវទ្រព្យសម្បត្តិសំខាន់ៗ** ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនដែលបានបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត រួមមាន រថយន្ត៩៤គ្រឿង, ម៉ូតូ២.២៨៥ គ្រឿង,ទូរស័ព្ទ៦.០២៩គ្រឿង,ជញ្ជីង៣៨២គ្រឿង,អាវុធខ្លី២៦ដើម,អាវុធវែង១៣ដើម, ប្រាក់កម្ពុជា៦២.៧៤៨.៣០០រៀល, ប្រាក់អាមេរិក ១៨.៥៧៥ ដុល្លារ, ប្រាក់ថៃ ២០.៥៩០ បាត , ប្រាក់វៀតណាម ៦.១០១.០០០ ដុង , ប្រាក់ចិន ២៤.០០០ យន់ និងអចលនទ្រព្យ៥កន្លែង រួមមាន ៖ ដីចំការ ១កន្លែង , ដីឡូតិ៍ ២កន្លែង និងផ្ទះល្វែង ២កន្លែង ។

– **ជនសង្ស័យចាប់ខ្លួនតាមដីកាមាន** ២៤១ ដីកា ឃាត់ខ្លួនជនសង្ស័យ ២៣៣ នាក់ (ស្រី៩នាក់) ។

៦ <u>បញ្ជាក់</u> ៖ តាមនិន្នន័យរបស់ក្រសួងយុត្តិធម៌នាឆ្នាំ២០១៨ នេះ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ចំណាត់ការរឿងក្តីបទល្មើសគ្រឿងញៀនបានចំនួន ៤.៦០៥ រឿង ជនល្មើសសរុបចំនួន ៧.៧៩៥ នាក់ ។

➢ **កត់សម្គាល់ ៖**

– ដើមឆ្នាំ២០១៨ សមត្ថកិច្ចបានបង្រ្កាបករណីនាំចូលស្លឹករុក្ខជាតិខាត(KHAT)ចំនួន០២ករណី ស្មើនឹង ៣.២២៧ គ.ក្រ(ក្រៀម) ធ្វើការបំផ្លាញចោល(ស្លឹកKhat ជារុក្ខជាតិមានផ្ទុកសារធាតុញៀនប្រភេទ Cathinone ដែលប្រទេសមួយចំនួនចាត់ទុកជាប្រភេទរុក្ខជាតិញៀន) ។ បច្ចុប្បន្ន អ.ជ.ប.គ.៣ តាមរយៈការស្នើសុំពីអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ បានដាក់បញ្ចូលប្រភេទរុក្ខជាតិ Khat ចូលក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយប្រកាសរបស់ក្រសួងសុខាភិបាល

– តាមរយៈកិច្ចប្រតិបត្តិការដេកពិសោធន៍ការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប សមត្ថកិច្ចធ្វើការបង្ក្រាបបានចំនួន**០៥ទីតាំង**(ឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធការជួញដូរគ្រឿងញៀនចំនួន **៣៥ នាក់ រួមមាន ជនបរទេស១១នាក់** បញ្ជូនទៅតុលាការផ្តន្ទាទោស) ក្នុងនោះរាជធានីភ្នំពេញ **០២ទីតាំង(ខារ៉ាអូខេ)** ខេត្តព្រះសីហនុ **០២ទីតាំង(ខារ៉ាអូខេ និងក្លឹបរាត្រី)** និងខេត្តសៀមរាប **០១ ទីតាំង** បង្ក្រាបនៅតាមក្លឹបកម្សាន្ត ។ ក្នុងខណៈពេលដូចគ្នានេះ នៅខេត្តបន្ទាយមានជ័យក៏បានធ្វលសកម្មភាពបង្ក្រាបនៅតាមក្លឹបកម្សាន្តចំនួន**០៣ទីតាំង** ដោយរកឃើញអ្នកប្រើប្រាស់គ្រឿងញៀនចំនួន **១០នាក់**។

➢ ដោយឡែក ៖

– ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិបានដុតបំផ្លាញវត្ថុតាងគ្រឿងញៀនតាមអំណាចសាលក្រម សាលដីកាស្ថាពររបស់សាលាដំបូងរាជធានីភ្នំពេញ ប្រមាណជិត**៦៤**គីឡូក្រាម

– ក្រសួងយុត្តិធម៌ បានដុតបំផ្លាញវត្ថុតាងគ្រឿងញៀនតាមអំណាចសាលក្រម និងសាលដីកាស្ថាពររបស់សាលាដំបូងខេត្តចំនួន១១គឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង ស្វាយរៀង កោះកុង សៀមរាប ស្ទឹងត្រែង ត្បូងឃ្មុំ តាកែវ ព្រះសីហនុ កំពត និងខេត្តកំពង់ស្ពឺ ប្រមាណជាង **១០០** គីឡូក្រាម ។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល ៖

អនុវត្តវិធានការរដ្ឋបាលបានចំនួន **៤.៥៩៨ លើក** ក្នុងនោះ បានអញ្ជើញម្ចាស់អាជីវកម្ម និងអ្នកពាក់ព័ន្ធមកស្តាប់ការណែនាំចំនួន **២៥៥ លើក** ស្មើនឹង **៧.១៩២ នាក់** ស្រី ២.០២៨ នាក់ និងចុះអប់រំម្ចាស់ទីតាំងអាជីវកម្មចំនួន**៤.៣៣៩ គោលដៅ(សណ្ឋាគារ ២១៩** ផ្ទះសំណាក់៨៨៨ ផ្ទះជួល៩៤៩ ក្លឹបកម្សាន្ត**៤៧** ខារ៉ាអូខេ**៣៩២** បារបរទេស៤៨ និងទីតាំងផ្សេងៗ **១.៧៩៦)** ។

ក្រៅពីនេះស្នងការដ្ឋាននគរបាលខេត្តចំនួន**១៧** បានចុះធ្វើតេស្តរកសារធាតុញៀនលើក្មេងទំនើង ជនមានតម្រុយប្រើគ្រឿងញៀន និងធ្វក់ត្រួតពិនិត្យអ្នកបើកបររថយន្តដឹកទំនិញ ដឹកកម្មករ ដឹកអ្នកដំណើរ បុគ្គលិកក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ ខារ៉ាអូខេ សរុបចំនួន **៨៥៩ លើក** ស្មើនឹង **៨.៥៦២ នាក់ ស្រី ១.៨០៦ នាក់ រកឃើញអ្នកផ្ទុកសារធាតុញៀន ១.៣០៥ នាក់** ត្រូវបានសមត្ថកិច្ចធ្វើការបញ្ជូនតាមនីតិវិធីច្បាប់ ឲ្យទៅទទួលយកសេវាបន្សាប និងព្យាបាល ។

➢ **កត់សម្គាល់** ៖ ដោយពិនិត្យឃើញការប្រែប្រួលយ៉ាងឆាប់រហ័សនៃការលួចដឹកជញ្ជូនយ៉ាងគំហុកចូលមកកម្ពុជានូវសារធាតុញៀនជាច្រើន ស្របពេលដែលស្ថានការណ៍នៃការរីករាលដាលការប្រើប្រាស់គ្រឿងញៀននៅតាមទីកន្លែងសប្បាយដ្ឋានមួយចំនួនផងនោះ លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ បានចាត់តាំងឲ្យមានកិច្ចប្រជុំដេកពិសោធន៍វាយតម្លៃសភាពការណ៍គ្រឿងញៀននៅប៉ូលទេសចរណ៍ចំនួន ៣ គឺ **រាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប** ។ តាមរយៈកិច្ចប្រជុំនេះ លេខាធិការដ្ឋានបានស្នើសុំគោល

ការណ៍ **សម្ដេចក្រឡាហោម** ប្រធានយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ដើម្បីចុះពង្រឹងការអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ ដោយកំណត់យករាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ធ្វើជាគោលដៅអាទិភាព ហើយយករាជធានីភ្នំពេញធ្វើសកម្មភាពដកពិសោធន៍ទូទាំងប្រទេស។

**៣.៤. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ៖**

មន្ទីរពិសោធន៍គ្រឿងញៀន នៃ អ.ជ.ប.គ.ញ. បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀនបានចំនួន **៤.៥៦៨** សំណាក = **៤.៣០៣** ករណី ក្នុងនោះ ៖

– **សំណាកវិជ្ជមានសារធាតុញៀន ៤.៤៣១** សំណាក (៩៧ %) = **៤.២១៣** ករណី គឺ ៖

- មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៤.០៩៧ សំណាក (៨៩,៦៨ %)
- មេតំហ្វេតាមីនគ្រាប់ (WY) ១៥៤ សំណាក (៣,៣៧ %) - កូកាអ៊ីន ១១ សំណាក (0,២៤%)
- ហេរ៉ូអ៊ីន ៤ សំណាក (0,0៨%) - កេតាមីន៥៥សំណាក(១,២0 %)
- MDMA ៨៨ សំណាក (១,៩២ %) - នីមេតាហ្សេប៉ាម១២សំណាក(0,២៦ %)
- កញ្ឆា ១0 សំណាក (0,២១ %)

– **សំណាកអវិជ្ជមានសារធាតុញៀន ១៣៧** សំណាក = **៩0** ករណី (២,៩៩%)

– ផ្តល់ដល់ស្ថាប័នអនុវត្តច្បាប់ រួមមាន អគ្គស្នងការដ្ឋាននគបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកដ្ឋានពន្ធនាគារ មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគបាល-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី-ខេត្ត គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត កងទ័ពជើងទឹក កងពលតូចលេខ ៧0 និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវ ៖

- ស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន សរុបចំនួន ១.៩00 សន្លឹក
- ម៉ាគ្វី ៩.៤៩0 តេស្ត តេស្តម៉ាគ្វីរកសារធាតុញៀន ១.៥00 មិល្លីលីត្រ កេតាមីន ៣៤៥ តេស្ត កូកាអ៊ីន ៥៤៦ តេស្ត ហេរ៉ូអ៊ីន ២៥ តេស្ត ឆិនការ ៦0 តេស្ត ស៊ីម៉ុនតេស្ត ៦00 មិល្លីលីត្រ តេស្តរកសារធាតុញៀនក្នុងទឹកនោមប្រភេទមេតំហ្វេតាមីន ៤៧.២0៥ តេស្ត តេស្តរកសារធាតុញៀនក្នុងទឹកនោមប្រភេទ(MDMA) ៨00តេស្ត និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនចំនួន ៣៧ ជញ្ជីង ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

ជាមួយនឹងការណែនាំឱ្យបង្កើនការយកចិត្តទុកដាក់គ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ វត្ថុធាតុដើម ព្រមទាំងសារធាតុផ្សំផ្សេងទៀត ដើម្បីបង្ការ និងទប់ស្កាត់ការបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់ យើងបានរៀបចំលិខិតបទដ្ឋានគិយុត្តពាក់ព័ន្ធ និងចូលសហការជាមួយក្រសួង-ស្ថាប័ន ក្នុងការគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ ដូចខាងក្រោម ៖

**៤.១.** បានរៀបចំកែសម្រួលសមាសភាពក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ

**៤.២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការប្រមូលព័ត៌មាន និងត្រួតពិនិត្យឯកសារការអនុញ្ញាតឲ្យនាំចូលនូវសារធាតុញៀននិងសាធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាក់ស្តែងក្នុងឆ្នាំ២០១៨ នាំចូលសរុបចំនួន ៦.៣0១.0៣២ គ.ក្រ ៥៤១ ក្រាម ១.000 មិល្លីក្រាម ក្នុងនោះ ៖

- តារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

– ក្រសួងឧស្សាហកម្ម និងសិប្បកម្មផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំចំនួន ៥.៤៦៩.២៥៧ គ.ក្រ

– ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុគីមីផ្សំ ចំនួន ៨៣0.៦៨0 គ.ក្រ

– ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលក្នុងទម្រង់ជាវត្ថុធាតុដើម ចំនួន ១៥០ គ.ក្រ និងក្នុងទម្រង់ជាសារធាតុផ្សំក្នុងឱសថចំនួន ១០២ ក្រាម ១២៣ មិល្លីក្រាម

➢ តារាងទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៖

ក្រសួងសុខាភិបាល បានផ្តល់អាជ្ញាប័ណ្ណនាំចូលសារធាតុញៀនក្នុងទម្រង់ជាវត្ថុធាតុដើម ចំនួន ៤៣៥ គ.ក្រ និងទម្រង់ជាសារធាតុផ្សំក្នុងឱសថ ចំនួន ៥១០ គ.ក្រ ៤៣៩ ក្រាម ៨៧៧ មិល្លីក្រាម ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ជាមួយនឹងការណែនាំឱ្យបន្តអនុវត្តនូវរាល់កិច្ចការដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គសម្រាប់ប្រទេសកម្ពុជា ឡាវ និង ថៃ ពិសេសការកសាងភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន នៅតាមបណ្តោយព្រំដែន ដែលភាគីកម្ពុជា ឡាវ ថៃ និងវៀតណាម បានឯកភាពគ្នា និងការពង្រឹងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) បន្ថែមទៀត នៅតាមព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម យើងបានចូលរួម និងសហការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយប្រទេសឡាវ ថៃ និងវៀតណាម ទាំងនៅក្នុង និងនៅក្រៅប្រទេសសរុបបានចំនួន **២៧** លើក ។

កម្មវិធីសំខាន់ៗ មានជាអាទិ៍ ៖

- ពង្រឹងការអនុវត្តផែនការ " ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន " និងបានប្រគល់សម្ភារសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)ចំនួន២កន្លែង និង " ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន " ចំនួន៣ភូមិ ជូនដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះវិហារ
- ប្រគល់សម្ភារសម្រាប់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)ចំនួន៣កន្លែង និង " ភូមិ-ឃុំ/សង្កាត់ ស គ្មានគ្រឿងញៀន " ចំនួន២ភូមិ ជូនដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង

(សម្ភារទាំងនោះ ជាជំនួយនៃគម្រោងសុវត្ថិភាពទន្លេមេគង្គនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និង កម្ពុជា-ឡាវ)

- ទស្សនកិច្ចសិក្សា ស្តីពីការរឹបអូស និងការចាត់ចែងទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀននៅប្រទេសថៃ ដើម្បីដកស្រង់បទពិសោធន៍សម្រាប់ប្រតិភូនៃគណៈកម្មការ ការតាមដាន ការប្រមូលការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- កិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ លើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តសៀមរាប
- សិក្ខាសាលាពិភាក្សាលើផែនការមេគម្រោងប្រតិបត្តិការសុវត្ថិភាពទន្លេមេគង្គ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន រយៈពេល៤ឆ្នាំ(២០១៩-២០២២) នៅខេត្តនគរណយុ ប្រទេសថៃ។
- សិក្ខាសាលាស្តីពីការស៊ើបអង្កេតបទល្មើសគ្រឿងញៀន និងការវិភាគគ្រឿងញៀន
- ចូលរួមប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលគម្រោងសុវត្ថិភាពទន្លេមេគង្គ (SMCC) រយៈពេល ៣ខែ នៅប្រទេសឡាវ
- វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន(BLO) នៅខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ត្រីភាគី/ទ្វេភាគី កម្ពុជា វៀតណាម ឡាវ លើកទី១៧ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ
- ចូលរួមពិធីបិទវគ្គមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ
- សិក្ខាសាលាស្តីពីការអភិវឌ្ឍន៍ផែនការសកម្មភាពក្នុងអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

ជាមួយនឹងការណែនាំឱ្យបន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ អង្គការ **UNODC** និងគម្រោងសហប្រតិបត្តិការជាមួយការិយាល័យអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ក៏ដូចជាគម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Project) ពិសេសពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែន**(BLO)** យើងបានចូលរួម និងសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដូចជា ការចូលរួមសន្និសីទ វេទិកាសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ កិច្ចប្រជុំប្រចាំឆ្នាំ វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ សិក្ខាសាលា និងទស្សនកិច្ចសិក្សានៅក្រៅប្រទេស សរុបបានចំនួន **២៨** លើក។

**កម្មវិធីសំខាន់ៗ មានជាអាទិ៍ ៖**

- កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន លើកទី៦ ស្តីពីបញ្ហាគ្រឿងញៀន នៅទីក្រុងហាណូយ(វៀតណាម)
- កិច្ចប្រជុំប្រមុខស្ថាប័នអនុវត្តច្បាប់គ្រឿងញៀនថ្នាក់ជាតិ (HONLEA) នៅទីស្នាក់ការអង្គការសហប្រជាជាតិប្រចាំទីក្រុងបាងកក ប្រទេសថៃ
- សន្និសីទជាន់ខ្ពស់ក្នុងតំបន់ ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ នៅប្រទេសភូមា
- សន្និសីទជាន់ខ្ពស់ក្នុងតំបន់ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន នៅប្រទេសឡាវ
- កិច្ចប្រជុំស្តីពីប្រតិបត្តិការតំបន់ត្រីកោណមាស ក្រោមផែនការកិច្ចសហប្រតិបត្តិការ៣ឆ្នាំ សម្រាប់គម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ នៅខេត្តឈៀងម៉ៃ ប្រទេសថៃ
- វគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដោយមានការចាត់តាំង នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ
- សន្និសីទ ស្តីពីកិច្ចប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន (ADEC-23) លើកទី២៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងតូក្យូ ប្រទេសជប៉ុន
- សិក្ខាសាលាអាស៊ាន ស្តីពីកិច្ចប្រតិបត្តិការបណ្តាញឃ្លាំមើលគ្រឿងញៀន លើកទី៥
- កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ(GBC) លើកទី១៣
- សិក្ខាសាលាអាស៊ាន ស្តីពីការងារស្ថិតិជំណាំគ្រឿងញៀនក្រោមគម្រោង ASEAN NARCO
- មហាសន្និបាត ស្តីពីនិរន្តរភាពនៃការអភិវឌ្ឍន៍ ការបង្ការបទឧក្រិដ្ឋទាក់ទងដំណាំគ្រឿងញៀន
- កិច្ចប្រជុំគណៈកម្មាធិការគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ លើកទី៦១
- សិក្ខាសាលាអាស៊ាន ស្តីពីការវិភាគផ្លូវចរាចរគ្រឿងញៀន និងសារធាតុគីមីផ្សំតាមដងទន្លេមេគង្គ
- វគ្គបណ្តុះបណ្តាលការអនុវត្តជាក់ស្តែង ស្តីពីការឆែកឆេរ ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស នៃកម្មវិធីត្រួតពិនិត្យកុងតឺន័រ
- វគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេត និងលុបបំបាត់ឧក្រិដ្ឋកម្មគ្រឿងញៀន នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ
- កិច្ចប្រជុំ ADLOMICO លើកទី២៨ ស្តីពីបញ្ហាគ្រឿងញៀន នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ
- កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់អាស៊ាន លើកទី៣៩ ស្តីពីបញ្ហាគ្រឿងញៀន នៅទីក្រុងបានដាសេរីបឺហ្គាវ៉ាន់ ប្រទេសប្រ៊ុយណេដារ៉ូសាឡឹម
- សិក្ខាសាលា ស្តីពីកម្មវិធី UNODC Global SMART Programme Regional ប្រចាំតំបន់ នៅទីក្រុងបាងកក ប្រទេសថៃ

- កិច្ចប្រជុំស្តីពីការត្រួតពិនិត្យគ្រឿងញៀនតាមអាកាសយានដ្ឋានលើកទី៨(AAITF)នៅខេត្តសៀមរាប
- កិច្ចប្រជុំបណ្តាញអនុវត្តច្បាប់(ក្នុងក្របខណ្ឌគម្រោងPATROL) ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែន នៅប្រទេសកែនយ៉ា អាហ្វ្រិក
- វគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន នៅប្រទេសឥណ្ឌា ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ជាមួយនឹងការណែនាំឱ្យបន្តរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការរៀបចំផ្សព្វផ្សាយព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ការរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការរៀបចំផែនការជាតិ៥ឆ្នាំ(២០១៩-២០២៣)ស្តីពីការត្រួតពិនិត្យគ្រឿងញៀន យើងបានពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈ៖

**៧.១.** ការបន្តដឹកនាំគណៈកម្មការទាំង៦ និងអនុគណៈកម្មការទាំង៣ នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ព្រមទាំងរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តផែនការនេះ។

**៧.២.** ការដឹកនាំអនុវត្តផែនការជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៦-២០១៨)។

**៧.៣.** ការដឹកនាំអនុវត្តតាមទិសដៅការងារដែលបានដាក់ចេញកាលពីឆ្នាំ២០១៧។

**៧.៤.** បានរៀបចំកែសម្រួលសមាសភាពក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

**៧.៥.** បានដាក់បញ្ចូលរុក្ខជាតិខាត (KHAT) ទៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដោយប្រកាសរបស់ក្រសួងសុខាភិបាល។

**៧.៦.** បានចុះផ្សព្វផ្សាយរបាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនប្រចាំនព្វមាស/២០១៨ នៅរាជធានី-ខេត្តគោលដៅ ។

## ៨. មូលនិធិជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ចាប់ពីពេលបង្កើតមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានកៀរគរ និងប្រមូលបានមូលនិធិសរុបចំនួន **៥.១៣២.៣២៣** ដុល្លារ(ប្រាំលាន មួយរយសាមសិបពីរពាន់ និងបីរយម្ភៃបីដុល្លារអាមេរិក) ដែលថវិកានេះបានមកពីការចូលរួមរបស់សប្បុរសជន តាមរយៈមូលនិធិជួយសង្គ្រោះអ្នកញៀនគ្រឿងញៀនរបស់**សម្តេចក្រឡាហោម** ចំនួន **៣២៩.៩២៨** ដុល្លារ(បីរយម្ភៃប្រាំបួនពាន់ និងប្រាំបួនរយម្ភៃប្រាំបីដុល្លារអាមេរិក) ការលក់ទ្រព្យសម្បត្តិដែលបានមកពីការរឹបអូសដីនិងផ្ទះ២កន្លែងចំនួន**១.៨០២.៣៩៥**ដុល្លារ (មួយលានប្រាំបីរយពីរពាន់ និងបីរយកៅសិបប្រាំដុល្លារអាមេរិក) និងនៅក្នុងឱកាសអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ កន្លងទៅ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម នាយករដ្ឋមន្ត្រី** នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅខេត្តព្រះសីហនុ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលវៀតណាម ក្នុងចំនួនទឹកប្រាក់៣លានដុល្លារអាមេរិក ។ ជាមួយគ្នានេះ កាលពីក្នុងអំឡុងឆ្នាំ២០១៧ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ បានផ្តល់ជំនួយក្នុងទឹកប្រាក់

ចំនួន **១.១៥៥.៣៦១** ដុល្លារអាមេរិក សម្រាប់ការសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀនផងដែរ មូលនិធិខាងលើត្រូវបានប្រើប្រាស់សម្រាប់ ៖

- ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- ការផ្តល់ការលើកសរសើរដល់មន្ត្រីអនុវត្តច្បាប់ និងការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀន ។

ជាមួយគ្នានេះ គណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន បានចុះទៅបំពេញការងារនៅតាមសាលាដំបូងខេត្តចំនួន១៦គឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ ព្រះវិហារ ឧត្តរមានជ័យ កំពង់ឆ្នាំង សៀមរាប កណ្តាល កំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ពោធិ៍សាត់ តាកែវ ប៉ៃលិន ត្បូងឃ្មុំ ក្រចេះ និងខេត្តស្ទឹងត្រែង ដើម្បីពន្លឿន និងជម្រុញនីតិវិធីចេញសេចក្តីសម្រេច ឬសាលក្រមនៃចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យក្នុងបទល្មើសគ្រឿងញៀន និងប្រមូលវត្ថុតាង មធ្យោបាយផ្សេងៗដែលបានរឹបអូសជាសម្បត្តិរដ្ឋតាមសាលក្រម សាលដីកាមិនទាន់ស្ថាពរ និងសាលក្រម សាលដីកាស្ថាពរ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

### ១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖

**ចំណុចខ្លាំង ៖**

ការងារអប់រំផ្សព្វផ្សាយមានគុណភាពជាងមុន ដោយសារយើង ៖

- បានរៀបចំឲ្យមានផែនការសកម្មភាពជាក់លាក់ និងមានលក្ខណៈពហុវិស័យ ដោយបានកំណត់នូវក្រុមគោលដៅ និងបែងចែកការទទួលខុសត្រូវច្បាស់លាស់ដល់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីធានាថាគ្រប់ក្រុមគោលដៅងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ បានទទួលសារ ឬការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន
- ផ្អែកទៅលើផែនការសកម្មភាពដែលបានកំណត់ ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនពីថ្នាក់រាជធានី-ខេត្ត រហូតដល់ថ្នាក់មូលដ្ឋានឃុំ-សង្កាត់ ភាគច្រើនបានយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់
- ជនបង្គោលរបស់ក្រសួង-ស្ថាប័ន ដែលបានបណ្តុះបណ្តាល ពួកគាត់បានចូលរួមធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀនយ៉ាងផុលផុស
- ទទួលបានការចូលរួម និងគាំទ្រកាន់តែច្រើនឡើងៗពីគ្រប់សមាសភាពសង្គម ពិសេសពីស្ថាប័នជាតិសំខាន់ៗ ដូចជា ព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា ក៏ដូចជាការចូលរួម និងគាំទ្រពីវិស័យសាសនា វិស័យឯកជន មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ លោកគ្រូ-អ្នកគ្រូ និស្សិត សិស្សានុសិស្ស ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ ទូរទស្សន៍ ប្រព័ន្ធទំនាក់ទំនងសង្គម រួមផ្សំជាមួយនឹងការចូលរួម និងគាំទ្រកាន់តែសកម្ម និងផុលផុសរបស់ប្រជាពលរដ្ឋ ធ្វើឲ្យការអប់រំផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀនកាន់តែបង្កលក្ខណៈងាយស្រួល និងកាន់តែស៊ីជម្រៅ ។ ជាមួយគ្នានេះ ក្រុមហ៊ុនផលិតកម្មភាពយន្ត និងចម្រៀង ក៏បានដំឡើងសារអប់រំពីបញ្ហាគ្រឿងញៀននៅក្នុងផលិតផលរបស់ខ្លួនជាច្រើនផងដែរ

**ចំណុចខ្វះខាត ៖**

- ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត(ដែលរួមមានយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ក្រុង ស្រុក ខណ្ឌ)មួយចំនួន នៅតែមិនទាន់បានយកចិត្តទុកដាក់ឲ្យអស់ពីលទ្ធភាព និងទទួលខុសត្រូវអនុវត្តឲ្យបានសកម្មនូវរាល់ភារកិច្ចដែលបានកំណត់ និងបែងចែកក្នុងផែនការសកម្មភាព

– ក្រសួង-ស្ថាប័ន អង្គភាព ក៏ដូចជាគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តខ្លះទៀត បានចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធនាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ បានសកម្មហើយ ប៉ុន្តែមិនបានផ្ញើរបាយការណ៍មកលេខាធិការដ្ឋាននៃផែនការយុទ្ធនាការឲ្យបានទៀងទាត់

– ក្រុមគោលដៅដែលប្រឈមខ្ពស់ ដូចជា ក្រុមពលករចល័ត ពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកជញ្ជូន អ្នកបម្រើសេវាកម្សាន្តសប្បាយ សិស្សគេចសាលា សិស្សបោះបង់ការសិក្សា នៅតែជាក្រុមគោលដៅដែលទទួលបានសារអប់រំផ្សព្វផ្សាយតិចជាងគេ។ ជាមួយគ្នានេះ ការបណ្តុះបណ្តាល និងការចាត់តាំង ចងក្រងក្រុមជនបង្គោលសម្រាប់ការអប់រំផ្សព្វផ្សាយ ក៏មិនទាន់គ្រប់គ្រាន់តាមស្ថានភាពនៃក្រុមគោលដៅ និងមុខសញ្ញាប្រឈម ដូចជា នៅតាមផ្ទះសំណាក់ ផ្ទះជួល ក្លឹបកម្សាន្ត ក៏ដូចជានៅតាមមូលដ្ឋានផលិតកម្មក្រៅប្រព័ន្ធ ។ល។ ឱ្យជាក់ស្តែងនៅឡើយ

– ការបិទផ្សាយសារអប់រំពីបញ្ហាគ្រឿងញៀននៅលើផលិតផល នៅតែមិនទាន់មានលក្ខណៈទូលំទូលាយ

– រដ្ឋបាលមូលដ្ឋានឃុំ-សង្កាត់ ក៏ដូចជា បណ្តាអង្គភាពពាក់ព័ន្ធនៅក្នុងមូលដ្ឋាន នៅតែមិនទាន់ទទួលខុសត្រូវដើរតួ ជាកម្លាំងជួរមុខក្នុងការបង្ការ ទប់ស្កាត់ និងដោះស្រាយរាល់បញ្ហា ដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀននៅក្នុង មូលដ្ឋានរបស់ខ្លួន ហើយភាគច្រើនពឹងផ្អែកទៅលើកិច្ចអន្តរាគមន៍ពីសមត្ថកិច្ចថ្នាក់លើ ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**ចំណុចខ្លាំង ៖**

– គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានពង្រឹងនិងពង្រីកការងារព្យាបាល និងលើកកម្ពស់សមត្ថភាពមន្ត្រីរបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន

– កិច្ចសហការកាន់តែល្អប្រសើររវាងក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ ពិសេសរវាងអង្គភាពអនុវត្តច្បាប់ ព្រះរាជអាជ្ញា តុលាការ និង មូលដ្ឋានផ្តល់សេវាសុខភាព

– ការកើនឡើងនូវការយល់ដឹង និងភ្ញាក់រលឹករបស់ប្រជាពលរដ្ឋ ក្នុងការបញ្ជូនកូនចៅដែលប្រើប្រាស់ ឬញៀនគ្រឿងញៀនឲ្យទៅទទួលយកសេវាព្យាបាល និងស្តារនីតិសម្បទា ។

**ចំណុចខ្វះខាត ៖**

– អាណាព្យាបាល និងអ្នកញៀនគ្រឿងញៀនមួយចំនួនមិនទាន់បានជម្រុញ នឹងស្ម័គ្រចិត្តទៅទទួលសេវាព្យាបាល និងស្តារនីតិសម្បទា ដែលបញ្ហានេះអាចបណ្តាលមកពីការខ្មាស់អៀន និងខ្លាចការរើសអើង ឬការមិនយល់ដឹងច្បាស់លាស់ពីការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា

– យន្តការនៃការថែទាំ ព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀន នៅមិនទាន់បានយកចិត្តទុកដាក់រៀបចំ និងបង្កើតឲ្យបានគ្រប់គ្រាន់នៅឡើយ។ ម៉្យាងទៀត ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបំណិនជីវិត ដល់អ្នកដែលបានជាសះស្បើយពីគ្រឿងញៀននៅមិនទាន់ឆ្លើយតបបានតាមតម្រូវការទីផ្សារការងារ

– នៅមិនទាន់មានប្រព័ន្ធថែទាំនៅក្រោយការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀន ឱ្យបានច្បាស់លាស់ ដើម្បីជានាតាមដានជនរងគ្រោះឱ្យមានប្រសិទ្ធភាព

– ការតាមដាន និងវាយតម្លៃលើការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងនៅតាមមណ្ឌលបណ្តោះអាសន្ន និងនៅតាមសហគមន៍ ធ្វើមិនទាន់បានទៀងទាត់ និងច្បាស់លាស់

– ការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀនដែលជាពិរុទ្ធជន-ទណ្ឌិត នៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅតែមិនទាន់បានរៀបចំ ។

– ការរៀបចំទិន្នន័យអ្នកញៀនគ្រឿងញៀនមិនមានលក្ខណៈជាប្រព័ន្ធ ហើយវិធីសាស្ត្រប្រមូល វិភាគ រក្សាទុក និងបញ្ជូនទិន្នន័យអ្នកញៀនគ្រឿងញៀន នៅមិនទាន់ច្បាស់លាស់

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**ចំណុចខ្លាំង ៖**

មន្ត្រីអនុវត្តច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទទួលបាននូវការគាំទ្រជាថវិកា និងការសរសើរលើកទឹកចិត្តតាមគ្រប់រូបភាព ពីគណៈដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងព្រមទាំងការបណ្តុះបណ្តាលជាបន្តបន្ទាប់ គួបផ្សំនឹងការអនុវត្តជាក់ស្តែង រួមជាមួយការប្រើប្រាស់កម្លាំងសរុប ធ្វើឲ្យការស្រាវជ្រាវស៊ើបអង្កេតបទល្មើសកាន់តែមានប្រសិទ្ធភាព ។ ជាមួយគ្នានេះ តាមរយៈកិច្ចសហការផ្តល់ព័ត៌មានរហ័សឲ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង និងស្ថាប័នអន្តរជាតិបានល្អ ធ្វើឲ្យសមត្ថកិច្ចទប់ស្កាត់ និងបង្ក្រាបបទល្មើសបានច្រើនករណីធំៗ ។ តាមរយៈ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣នេះ បានធ្វើឲ្យជះឥទ្ធិពលដល់បទល្មើសផ្សេងៗ ជាពិសេសបទល្មើសព្រហ្មទណ្ឌមានការថយចុះ ។

**បញ្ហាប្រឈម ៖**

– ឧក្រិដ្ឋជនអន្តរជាតិ នៅតែព្យាយាមប៉ុនប៉ងប្រើប្រាស់កម្ពុជា ធ្វើជាប្រទេសផលិតកែច្នៃ និងឆ្លងកាត់គ្រឿងញៀនខុសច្បាប់តាមគ្រប់រូបភាព ទាំងផ្លូវគោក ផ្លូវទឹក អាកាស និងបញ្ញើប្រៃសណីយ៍

– បណ្តាខេត្តនៅភាគឦសានប្រទេស នៅតែជាខេត្តដែលបន្តមានសកម្មភាពចរាចរឆ្លងកាត់គ្រឿងញៀនដោយខុសច្បាប់ ទោះបីយើងបង្ក្រាបបានចំករណីធំៗ និងកាត់ផ្តាច់ខ្សែរយៈទាក់ទងជាច្រើនហើយក៏ដោយ ។

**ចំណុចខ្វះខាត ៖**

–ការគ្រប់គ្រងគោលដៅភូមិសាស្ត្រ និងមុខសញ្ញាដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនមិនបានហ្មត់ចត់

–ការជួញដូរ ការប្រើប្រាស់គ្រឿងញៀន នៅតែមានការកើនឡើងនៅតាមទីតាំងមួយចំនួនដូចជា ផ្ទះសំណាក់ ផ្ទះជួល អាជីវកម្ម សេវាកម្មកម្សាន្ត និងតំបន់ស្មុគស្មាញមួយចំនួន

–វិធានការបង្កក រឹបអូស និងលក់ទ្រព្យ មានភាពយឺតយ៉ាវ មិនឆ្លើយតបទៅនឹងសំណូមពររបស់មូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន

–មធ្យោបាយ សម្ភារ សម្រាប់បម្រើឲ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀននៅតែជាបញ្ហាចោទចំពោះមុខដែលត្រូវដោះស្រាយ ពិសេសនៅថ្នាក់មូលដ្ឋាន ។

–គោលដៅដែលកើតបទល្មើសគ្រឿងញៀន គឺជាគោលដៅដដែលៗ អាចបណ្តាលមកពីការញញើតញញើម ឬមានផលប្រយោជន៍ ដែលនាំឱ្យការងារអនុវត្តច្បាប់មិនមានប្រសិទ្ធភាព

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**ចំណុចខ្លាំង ៖**

ដោយមានកិច្ចសហការល្អជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ យើងគ្រប់គ្រងបានជាប់ជាប្រចាំនូវទិន្នន័យសារធាតុគីមីផ្សំដែលមានការអនុញ្ញាតឲ្យនាំចូល ។ តាមរយៈការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីអនុវត្តច្បាប់យើងកាន់តែមានបទពិសោធន៍ក្នុងការបង្ការ ទប់ស្កាត់បានការបង្វែរសារធាតុគីមីផ្សំ ពីជំនួញស្របច្បាប់ យកទៅសំយោគផលិតជាគ្រឿងញៀនខុសច្បាប់ ។

**ចំណុចខ្វះខាត ៖**

–យន្តការការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ មិនទាន់ដំណើរការពេញលេញ

–ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យសារធាតុគីមីផ្សំដល់សមត្ថកិច្ចពាក់ព័ន្ធ និងបុគ្គលិកក្រុមហ៊ុនឧស្សាហកម្មគីមី នៅមិនទាន់ធ្វើបានទូលំទូលាយនៅឡើយ

–នៅមិនទាន់មានការត្រួតពិនិត្យបានច្បាស់លាស់ពីការចរាចរ ការប្រើប្រាស់ និងសន្និធិសារធាតុគីមីផ្សំ ដែលប្រើប្រាស់ដោយសិប្បកម្មក្នុងស្រុកនានា ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**ចំណុចខ្លាំង ៖**

កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងយន្តការនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ផែនការសកម្មភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលក្នុងនោះមានសកម្មភាពមួយចំនួនត្រូវបានកំណត់ជាអាទិភាព៖

– ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីអនុវត្តច្បាប់នៅទូទាំងប្រទេស

– ការផ្តល់មធ្យោបាយ សម្ភារៈ បរិក្ខារចាំបាច់មួយចំនួនជួយសម្រួលដល់សេចក្តីត្រូវការចំពោះមុខ និងការផ្តល់ថវិកា ដើម្បីទ្រទ្រង់សកម្មភាពអាទិភាពត្រួតពិនិត្យគ្រឿងញៀន

– ការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកទាក់ទងនឹងបទល្មើសគ្រឿងញៀន ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការត្រីភាគី និងទ្វេភាគី បានធ្វើឡើងយ៉ាងសកម្មនិងផុលផុស ដើម្បីឈានទៅទប់ស្កាត់ និងបង្ក្រាបទាន់ពេលនូវករណីជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែន

– យើងបានឯកភាពគ្នាជាមួយភាគីឡាវ ថៃ និងវៀតណាម ដើម្បីរៀបចំកសាង " ភូមិ-ឃុំ/សង្កាត់ ស្អាតគ្មានគ្រឿងញៀន " នៅតំបន់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-ថៃ និងឈានទៅបង្កើតបន្ថែមទៀតនៅតំបន់ព្រំដែនកម្ពុជា-វៀតណាម (រវាងខេត្តតាកែវ និងខេត្តអាងយ៉ាង)

– បានយកចិត្តទុកដាក់ក្នុងការពង្រឹង ពង្រីកការិយាល័យទាក់ទំនងព្រំដែន (BLO) បន្ថែមទៀតនៅតំបន់ដែលទទួលរងដោយការគំរាមកំហែងពីគ្រឿងញៀន

**ចំណុចខ្វះខាត៖**

ទោះបីជាយើងបានសហការជាមួយប្រទេសជិតខាងទទួលបានលទ្ធផលជាច្រើនក៏ពិតមែន ប៉ុន្តែការជួញដូរគ្រឿងញៀនឆ្លងកាត់ព្រំដែនប្រទេសកម្ពុជា ទៅកាន់ទីផ្សារគ្រឿងញៀនខុសច្បាប់ក្នុងតំបន់ និងពិភពលោកនៅតែបន្តកើតមាន។ ជាមួយគ្នានេះ ការងារត្រួតពិនិត្យគ្រឿងញៀន នៅតាមតំបន់សមុទ្រ និងនៅតាមប្រលានយន្តហោះនៃខេត្តព្រះសីហនុ នៅពុំទាន់ត្រូវបានពង្រឹងឱ្យបានហ្មត់ចត់នៅឡើយ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

**ចំណុចខ្លាំង ៖**

កម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន តាមរយៈការគាំទ្រ និងចូលរួមអនុវត្តផែនការសកម្មភាពនានា រួមមាន៖

– ក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ ក្រោមការសម្របសម្រួលរបស់អង្គការ UNODC

– ការអនុវត្តផែនការយុទ្ធសាស្ត្រនៃគម្រោងសុវត្ថិភាពទន្លេមេគង្គ និងមេគង្គក្រោម ដែលសម្របសម្រួលដោយប្រទេសថៃ

– ការអនុវត្តផែនការសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានានៅក្រៅតំបន់ជាមួយប្រទេសចិន និងសាធារណរដ្ឋកូរ៉េ ជាលទ្ធផល សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់កម្ពុជាកំពុងដើរតួនាទីយ៉ាងសកម្ម និងបានរួមចំណែកជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងពិភពលោក លើការងារតស៊ូបង្ក្រាបបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋកម្ម ឈានទៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនពីតំបន់ផលិត និងលុបបំបាត់តម្រូវការគ្រឿងញៀនក្នុងបណ្តាប្រទេសពាក់ព័ន្ធ។

**ចំណុចខ្វះខាត៖**

ទោះបីយើងបានធ្វើសកម្មភាពលេចធ្លោដូចបានជម្រាបជូនខាងលើក្តី តែការជួយគាំទ្រជាថវិកា មធ្យោបាយ និងសម្ភារពីបណ្តាប្រទេសផ្តល់ជំនួយ ក៏ដូចជាដៃគូអភិវឌ្ឍន៍នានាលើសកម្មភាពត្រួតពិនិត្យគ្រឿងញៀនបានកាត់បន្ថយមកនៅក្នុងកម្រិតតិចតួចបំផុត ដែលទាំងអស់នេះបានជះឥទ្ធិពលមិនល្អ និងធ្វើឲ្យសកម្មភាពត្រួតពិនិត្យគ្រឿងញៀនមានភាពអសកម្មដោយអន្លើ ទាំងនៅកម្ពុជា និងក្នុងតំបន់ទាំងមូល។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖**

**ចំណុចខ្លាំង ៖**

– ការបន្តដាក់ចេញនូវផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការបន្តពុះពារលុបបំបាត់គ្រឿងញៀននៅកម្ពុជា ដោយទទួលបាននូវការគាំទ្រ និងវាយតម្លៃខ្ពស់ពីគ្រប់មជ្ឈដ្ឋាន

– យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានស្រាប់បានដំណើរការងារប្រកបដោយឆន្ទៈមោះមុត និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការចាត់តាំងដឹកនាំអនុវត្តផែនការសកម្មភាពទៅតាមសមត្ថកិច្ចរៀងៗខ្លួន ជាពិសេសការអនុវត្តនូវវិធានការទាំង៥ នៃផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ធ្វើឲ្យទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់។

**ចំណុចខ្វះខាត ៖**

–យន្តការត្រួតពិនិត្យគ្រឿងញៀនរបស់រាជធានី-ខេត្តមួយចំនួន អនុវត្តមិនទាន់បានជាលក្ខណៈពហុវិស័យ

–បានបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់សង្កាត់-ឃុំរួចហើយ តែសកម្មភាពការងារមិនទាន់អនុវត្តបានជាប្រចាំ មិនទាន់បានរៀបចំយន្តការ និងការចាត់តាំងអនុវត្តឲ្យបានក្លៀវក្លា ក៏ដូចជាការជំរុញលើកទឹកចិត្តលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

– តាមរយៈ ការអនុវត្តច្បាប់កន្លងមក ទាមទារត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលត្រូវការរយៈពេលមួយយូរបង្គួរ ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅការងារ ឆ្នាំ២០១៩ (ទិសដៅការងារលម្អិតមាននៅក្នុងឯកសារឧបសម្ព័ន)

ផ្អែកលើការសន្និដ្ឋានវាយតម្លៃ និងការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយផ្អែកតាមវិធានការយុទ្ធសាស្ត្រនៃផែនការជាតិ ស្តីពីកាត្រួតពិនិត្យគ្រឿងញៀន បានដាក់ចេញទិសដៅសម្រាប់អនុវត្តនៅឆ្នាំ២០១៩ ដូចខាងក្រោម ៖

**១. ការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖**

**១.១.** បន្តការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាសាធារណៈ ពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ក្រុមគោលដៅប្រឈម និងងាយប្រឈមនឹងគ្រោះថ្នាក់ ក៏ដូចក្រុមយុវវ័យ ក្រុមពលករចល័ត ក្រុមពលករចំណាកស្រុក កម្មករសំណង់ កម្មកររោងចក្រ អ្នកបើកបររថយន្តដឹកទំនិញ និងដឹកអ្នកដំណើរ អ្នកបំរើសេវាកំម្សាន្តសប្បាយ ។ល។

**១.២.** បន្តរៀបចំកម្មវិធីប្រឡងកំណាព្យ គំនូរ កីឡា ចម្រៀង តន្ត្រី អប់រំពីបញ្ហាគ្រឿងញៀននូវតាមបណ្តាគោលដៅ ក៏ដូចជាការបញ្ជ្រាបខ្លឹមសារអប់រំបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីប្រគុំតន្ត្រី ផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជន និងក៏ដូចជាការបន្តរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងអំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងកម្មវិធីបុណ្យជាតិ និងអន្តជាតិធំៗ។ល។

**១.៣.** រៀបចំផែនការសកម្មភាព ផែនការតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តការងារលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីបញ្ហាគ្រឿងញៀន ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលជនបង្គោលនៅតាមក្រសួង-ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ពិសេសមូលដ្ឋានឃុំ/សង្កាត់ ឱ្យចូលរួមជាកម្លាំងជួរមុខក្នុងការអប់រំផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ បញ្ហាគ្រឿងញៀននៅមូលដ្ឋានរបស់ខ្លួន។

**១.៤.** បន្តរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយតាមរយៈការចុះចែកខិតប័ណ្ណ កូនសៀវភៅអប់រំ និងការបិតផ្ទាំងរូបភាព ឬសារអប់រំផ្សេងទៀត នៅតាមគោលដៅគ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស ការដ្ឋានសំណង់ កសិដ្ឋាន លំនៅដ្ឋានកម្មករ និងលើយានយន្ត។ល។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន ៖**

**២.១.** បន្តការងារសាងសង់មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងពិនិត្យលទ្ធភាពកសាងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនមួយកន្លែងទៀត សម្រាប់បណ្តាខេត្តនៅទិសឦសាន ។

**២.២.** បន្តជម្រុញការព្យាបាល និងស្តារនីតិសម្បាទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍តាមរយៈសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀនរបស់ក្រសួងសុខាភិបាល។

**២.៣.** បន្តរៀបចំផែនការ និងគោលនយោបាយជាតិសម្រាប់ការងារព្យាបាល និងស្តារនីតិសម្បាទាអ្នកញៀនគ្រឿងញៀន រួមទាំងឯកសារគោលសំខាន់ៗ និងចំបាច់នានា ដើម្បីធានាថាការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បាទាមានលក្ខណៈជាពុហុវិស័យ និងជាប្រព័ន្ធ។ ទន្ទឹមនោះ បន្តធ្វើបច្ចុប្បន្នភាពលើទិន្ន័យអ្នកញៀគ្រឿងញៀនឱ្យបានសុក្រិត ដែលអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការលើកកំម្ពស់គុណភាពព្យាបាល និងប្រសិទ្ធភាពក្នុងការផ្តល់សេវា។

**២.៤.** បន្តការគាំទ្រឱ្យបានពេញលេញ ពិសេសពាក់ព័ន្ធការបញ្ជូនអ្នកញៀនគ្រឿងញៀនឱ្យទៅទទួលការព្យាបាល ក៏ដូចជាការផ្តល់ការស្តារនីតិសម្បាទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត និងការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍វិញ។

**២.៥.** រៀបចំគោលនយោបាយជាក់លាក់ ស្តីពីការធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនសម្រាប់ធ្វើការតាមដាន នៅពេលពួកគេវិលត្រលប់ទៅសហគមន៍វិញ ដោយរួមបញ្ចូលទាំងអ្នកញៀនគ្រឿងញៀនដែលស្ថិតនៅក្នុងបណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី-ខេត្ត។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់ ៖**

**៣.១.** ជំរុញការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីគ្រឿងញៀន ដូចជា អនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញា ស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងទៅនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៨៨ និងអនុសញ្ញា ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង ឱ្យកាន់តែមានប្រសិទ្ធភាព។

**៣.២.** បន្តពង្រឹង និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន(BLO) និងការលើកកំម្ពស់សមត្ថភាពជំនាញដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន ក៏ដូចជាកាពង្រឹងការអនុវត្តច្បាប់ដើម្បីគាំទ្រដល់កម្មវិធីកាត់បន្ថយគ្រោះថ្នាក់។

**៣.៣.** បង្កើនកិច្ចសហប្រតិបត្តិការទប់ស្កាត់បញ្ហាគ្រឿងញៀន និងពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័នអនុច្បាប់ ។

៣.៤. បង្កើនប្រសិទ្ធភាពទប់ស្កាត់ជាអាទិភាពនូវការហូរចូលគ្រឿងញៀននៅតំបន់ព្រំដែនកម្ពុជា-ឡាវ នៅតាមព្រលានយន្តហោះ និងបញ្ញើរប្រៃសណីយ៍ ដោយការពង្រឹងការប្រមូលព័ត៌មានពីគ្រប់ប្រភព សំដៅវែកមុខពួកឧក្រិដ្ឋជនទាំងក្នុង និងក្រៅប្រទេស ឈានទៅបង្ក្រាបបាននូវបណ្តាញជួញដូរគ្រឿងញៀនទាំងនោះ។ជាមួយគ្នានេះត្រូវយកចិត្តទុកដាក់ទៅលើគោលដៅប្រឈមនានា ដូចជា កន្លែងកម្សាន្តសប្បាយ ។ល។ ព្រលានយន្តហោះខេត្តព្រះសីហនុ និងតាមផ្លូវសមុទ្រ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖**

**៤.១.** បង្កើនការគ្រប់គ្រងសារធាតុគីមីផ្សំគ្រឿងញៀន និងសារធាតុញៀនដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។

**៤.២.** ជំរុញការរៀបចំបទបញ្ញត្តិនានា និងកសាងផែនការ ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ និងសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងបណ្តុះបណ្តាលជំនាញដល់ ស្ថាប័នអនុវត្តច្បាប់។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖**

**៥.១.** បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាងតាមគ្រប់រូបភាព ដើម្បីពង្រឹងយន្តការត្រួតពិនិត្យ និងទប់ស្កាត់ការចរាចរគ្រឿងញៀន តាមផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ។

**៥.២.** បន្តពង្រឹងយន្តការ និងពង្រីកការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-ឡាវ / កម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ដោយផ្អែកតាមអនុសាសន៍ណែនាំរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការឈរជើងនៅតាមច្រកទ្វាព្រំដែន ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនេះ ត្រូវដំណើរការឱ្យស្របទៅនឹងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

**៥.៣.** ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ទាំងនៅក្នុងសកលលោក ក្នុងតំបន់ និងប្រទេសជាប់ព្រំដែន តាមគ្រប់យន្តការ ទ្វេភាគី ត្រីភាគី ពហុភាគី ដើម្បីទប់ស្កាត់ការចរាចរ និងការប្រើប្រាស់ គ្រឿងញៀននៅតាមព្រំដែន ពិសេស ការដាក់ឱ្យអនុវត្តនូវគោលនយោបាយ **ឃុំ-សង្កាត់ ស គ្មានគ្រឿងញៀន** នៅតាមបណ្តោយព្រំដែនប្រទេសជិតខាងកម្ពុជា ។ ចំពោះមុខស្នើសុំឱ្យខេត្ត ក្រុង ជាប់ព្រំដែន ត្រូវជ្រើសរើស ឃុំមួយ ក្នុងខេត្ត ដើម្បីអនុវត្តផែនការភូមិ ឃុំ-សង្កាត់ ស គ្មានគ្រឿងញៀន ។ ជាមួយគ្នានេះ ត្រូវបន្តសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ដើម្បីគាំទ្រការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ។

**៥.៤.** បន្តពង្រឹងការងារត្រួតពិនិត្យគ្រឿងញៀននៅតាមផ្លូវសមុទ្រ និងនៅព្រលានយន្តហោះនៃខេត្តព្រះសីហនុ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖**

**៦.១.** បន្តបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិត្យគ្រឿងញៀន ពិសេសពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ ដើម្បីស្វែងរកមូលនិធិគាំទ្រលើការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

**៦.២.** បន្តកៀរគរបណ្តាប្រទេសផ្តល់ជំនួយនិងដៃគូអភិវឌ្ឍន៍នានា ពិសេសអង្គការ UNODC ដើម្បីគាំទ្រសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា តាមរយៈការអនុវត្តផែនការសកម្មភាពរបស់បណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ ។

**៦.៣.** បន្តពង្រឹង និងពង្រីកការអនុវត្តកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអនុសញ្ញាគ្រឿងញៀនអន្តរជាតិ ព្រមទាំងបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសនានា ដើម្បីស្វែងរកការគាំទ្រសម្រាប់សកម្មភាពត្រួតពិនិគ្រឿងញៀន។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.១.** ពង្រឹងយន្តការសេនាធិការ ដើម្បីអនុវត្តការដឹកនាំពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីជំរុញប្រសិទ្ធិភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនទទួលបានលទ្ធផលល្អប្រសើរ និងមាននិរន្តរភាពទាំងការងារតាមដានបូកសរុបរាយការណ៍និងវាយតម្លៃសភាពការណ៍គ្រឿងញៀន ។ល។

**៧.២.** បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តដល់អង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរួមមាន ស្នាដៃលើការងារផ្សព្វផ្សាយអប់រំ ស្នារដៃការព្យាបាលនិងស្តារនីតិសម្បទា ស្នាដៃក្នុងការអនុវត្តច្បាប់ លើកទឹកចិត្តចំពោះអតីតអ្នកញៀនគ្រឿងញៀន ក្រុមគ្រួសារ និងសហគមន៍របស់គេ ។

**៧.៣.** បន្តជម្រុញការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាព។

**៧.៤.** បន្តពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់នៃយន្តការត្រួតពិនិត្យគ្រឿងញៀន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងចូលរួមឱ្យបានកាន់តែសកម្មក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

**៧.៥.** បន្តអនុវត្តគោលនយោបាយ និងលើកទឹកចិត្តដល់អង្គភាព បុគ្គលមានស្នាដៃពិតប្រាកដក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ រួមទាំងវិស័យឯកជន ។

**៧.៦.** ក្រុមការងារអគ្គលេខាធិការដ្ឋាន អ.ញ.គ.ប.ជ. និងក្រុមការងារដឹកនាំការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ត្រូវរៀបចំបញ្ចូលសមាសភាពរបស់គណៈកម្មការភូមិ ឃុំ-សង្កាត់ ស គ្មានគ្រឿងញៀន និងគណៈកម្មការទ្រទ្រង់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ទៅក្នុងសមាសភាពគណៈកម្មការដឹកនាំ និងអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពនៅគ្រប់លំដាប់ថ្នាក់ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ដែលតែងតែណែនាំ និងតម្រង់ទិសលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដែលបានដឹកនាំយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១ លើកទី២ និងលើកទី៣ ទទួលបានជោគជ័យយ៉ាងធំធេង ប្រកបដោយការទទួលខុសត្រូវ មានការគាំទ្រ និងវាយតម្លៃខ្ពស់ពីសាធារណមតិជាតិ អន្តរជាតិ ក៏ដូចជាប្រជាពលរដ្ឋទូទៅ ។

សូមថ្លែងអំណរគុណផងដែរ ដល់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យសាសនា បុគ្គលពាក់ព័ន្ធ ក៏ដូចជាសមាគមសង្គ្រោះ និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការគាំទ្រ ការកសាងមជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ និងនៅកន្លែងផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។សូមអរគុណចំពោះដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន សប្បុរសជន សិល្បករ និងជាប្រជាពលរដ្ឋ ដែលបានរួមចំណែកជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការធ្វើឲ្យបានសម្រេចលទ្ធផលជាផ្លែផ្កាដូចមានក្នុងរបាយការណ៍នេះ ។

សំណូមពរអំពាវនាវដល់ផ្នែកពាក់ព័ន្ធទាំងអស់ ដើម្បីរួមចំណែកដល់ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ និងទិសដៅការងាររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០១៩ ដើម្បីនាំមកនូវលទ្ធផលកាន់តែល្អប្រសើរ ជានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ថែរក្សានូវសុខុមាលភាព និងធនធានមនុស្សរបស់កម្ពុជាយើង ។

**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ចម្លងជូន** :
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-ក្រសួងសមាជិក អ.ជ.ប.គ.ញ.
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ.
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត
-នាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ


របាយការណ៍ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៨ ២៣ / ២៣